នៅរសៀល ថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) បានប្រារព្ធមហាសន្និបាតប្រចាំឆ្នាំលើកទី ១៩ របស់ខ្លួនតាមរយ: Zoom Meeting ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។ មហាសន្និបាតប្រចាំឆ្នាំនេះ ត្រូវបានធ្វើឡើង ដើម្បីរាយការណ៍ជូនសមាជិករបស់វិទ្យាស្ថាននៅសកម្មភាព ក៏ដូចជាសមិទ្ធផលដែល **វ.គ.ស.ក.** បានអនុវត្ត និងសម្រេចបានក្នុងឆ្នាំ២០២១កន្លងមក ការយល់ស្របទៅលើរបាយការណ៍ហិរញ្ញវត្ថុ២០២១ ដែលបានធ្វើសវនកម្មរួច និងការជ្រើសរើសសវនករឯករាជ្យសម្រាប់ឆ្នាំ២០២២របស់វិទ្យាស្ថាន។ ជាងនេះទៅទៀត មហាសន្និបាតឆ្នាំនេះ បានរៀបចំការប្រកាសនៅលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល២រូបថ្មី សម្រាប់បំពេញកូរ៉ុមក្រុមប្រឹក្សាភិបាលអាណត្តិទី៦បន្ត (**២០២២ - ២០២៤**) ដែលការបោះឆ្នោតនេះបានរៀបចំឡើងតាមរយៈអេឡិចត្រូនិច (Online Platform) និងបានជ្រើសរើសប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលថ្មីមកជំនួសប្រធាននិងអនុប្រធានក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន។

ឯកឧត្តម ក៏បានចូលរួមអបអរសាទរជាមួយសមាជិកក្រុមប្រឹក្សាភិបាលថ្មីចំនួន២រូប និងអបអរសាទរជាមួយលោកប្រធាន និងលោកអនុប្រធានក្រុមប្រឹក្សាភិបាលថ្មី សម្រាប់អាណត្តិទី៦ គិតចាប់ពីឆ្នាំ២០២២-២០២៤ ដែលទទួលបាននូវសំឡេងគាំទ្រតាមរយៈការបោះឆ្នោតរួមមាន÷

| | | | |
|---|---|---|---|
| ១. លោក ឃុន ដារិទ្ធ | ប្រធាន | ២. លោក ហុង ពិសិដ្ឋ | អនុប្រធាន |
| ៣. កញ្ញា ឆាយ បូរ៉ានីល | ហេរញ្ញិក | ៤. លោក គង់ ស៊ិនរ៉ា | សមាជិក |

និងកោតសរសើរចំពោះការលះបង់របស់ លោកប្រធាន **សាយ សុខខេង** និងលោកអនុប្រធាន **ស៊ឹម ចាន់គីរីរ័ត្ន** ក្នុងការជួយជ្រោមជ្រែង និងលើកស្ទួយវិជ្ជាជីវៈគណនេយ្យនិងសវនកម្មរបស់យើងកន្លងមក។

ជាចុងបញ្ចប់នៃកម្មវិធី លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលថ្មីបានប្រកាសឆន្ទៈដ៏មុតមាំក្នុងការបន្តការអភិវឌ្ឍវិទ្យាស្ថានឲ្យកាន់តែមានភាពរីកចម្រើន។

--- ២៩ ខែមិថុនា ឆ្នាំ២០២២ ---










--- ២៩ ខែមិថុនា ឆ្នាំ២០២២ ---

KICPAA

## លិខិតអបអរសាទរ

គោរពជូន

**ឯកឧត្តម ងី តាយី**

**រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

សូមចូលរួមអបអរសាទរ ឯកឧត្តម ដែលទទួលបានសមាជិកភាព សមាជិកកត្តិយស ទី១ ពី វ.គ.ស.ក. ចំពោះការចំណាយពេលវេលានិងកម្លាំងកាយចិត្ត ចូលរួមដឹកនាំនិងអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជាអស់រយៈពេលជាង ២៥ឆ្នាំកន្លងមកនេះ។ គុណូបក្ការៈដ៏ធំធេងនេះ នឹងក្លាយជាគំរូវីរភាពសម្រាប់អ្នកបន្តវេនជំនាន់ក្រោយ។

សូម ឯកឧត្តម ជួបប្រទះតែ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពអបអរសាទរពី**

**ក្រុមប្រឹក្សាភិបាល សមាជិក និងលេខាធិការដ្ឋាន នៃ វ.គ.ស.ក.**







## វគ្គបណ្តុះបណ្តាលស្តីពី សវនកម្មពន្ធដារ

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**)មានការសហការជាមួយ **Fii & Associate Co.,Ltd.** ដោយបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី“ សវនកម្មពន្ធដារ” នៅថ្ងៃព្រហស្បតិ៍ ទី ៣០ ខែមិថុនា ឆ្នាំ ២០២២ ចាប់ពីម៉ោង ៩: ០០ ព្រឹក ដល់ ១១: ៣០ ព្រឹក។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) សម្រាប់សមាជិក KICPAA និងទីផ្សារគណនេយ្យដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងដោយជោគជ័យដោយទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកចូលរួមចំនួនជាង ៤៦០នាក់។

--- ៣០ ខែមិថុនា ឆ្នាំ២០២២ ---








## សិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពី ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

សិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពី “**ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**” បានរៀបចំឡើងកាលពីថ្ងៃ០១ ខែកក្កដា ឆ្នាំ២០២២ ដោយមានការចែករំលែកបទពិសោធន៍ពីវាគ្មិនកិត្តិយស លោក **សេង តុលា** សាស្ត្រាចារ្យនៅវិទ្យាស្ថានខេមអេដ។ សិក្ខាសាលានេះបានទទួលជោគជ័យ ដោយមានការចូលរួមជាច្រើនពីសាកលវិទ្យាល័យដែលជាដៃគូរបស់ **វ.គ.ស.ក.** និងស្ថាប័នផ្សេងៗទៀត។

--- ១ ខែកក្កដា ឆ្នាំ២០២២ ---








## វគ្គបណ្តុះបណ្តាលស្តីពី Transfer Pricing

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**)មានការសហការជាមួយ **ALLNISON AUDITING AND CONSULTING CO.,LTD.** ដោយបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “**Transfer Pricing**” នៅថ្ងៃចន្ទ ទី ២៤ ខែតុលា ឆ្នាំ២០២២ ពីម៉ោង ៩:៣០ ព្រឹក ដល់ ១១:៣០ ព្រឹក។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) សម្រាប់សមាជិក KICPAA និងទីផ្សារគណនេយ្យដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងដោយជោគជ័យដោយទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកចូលរួមចំនួនជិត ៥០០នាក់។

--- ២៤ ខែតុលា ឆ្នាំ២០២២ ---








## សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី ការណែនាំអំពីគំរូអាជីវកម្ម

នាថ្ងៃព្រហស្បតិ៍ ២ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ **វ.គ.ស.ក.** បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី “**ការណែនាំអំពីគំរូអាជីវកម្ម**” ដោយមានការចូលរួមពីវាគ្មិនកិត្តិយស បណ្ឌិត **គា បូរ៉ា** Director of Finance and Corporate Affairs of Edotco (Cambodia) Co., Ltd.។ សិក្ខាសាលានេះជាផ្នែកមួយនៃការគាំទ្រមុខវិជ្ជាទី៤ស្តីពី ការណែនាំអំពីអាជីវកម្ម នៃកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)។ សិក្ខាសាលានេះបានទទួលជោគជ័យ ដោយមានការចូលរួមជាច្រើនដែល មកពីសាកលវិទ្យាល័យដែលជាដៃគូរបស់ **វ.គ.ស.ក.** និងស្ថាប័នផ្សេងៗទៀត។

--- ២៧ ខែតុលា ឆ្នាំ២០២២ ---








## វគ្គបណ្តុះបណ្តាលស្តីពី CIFRS 9

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) មានការសហការជាមួយ **ERNST & YOUNG (CAMBODIA) LTD.** ដោយបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**CIFRS 9**" នៅថ្ងៃសុក្រ ទី ២៨ ខែតុលា ឆ្នាំ ២០២២ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ១១:៣០ ព្រឹក។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) សម្រាប់សមាជិក KICPAA និងទីផ្សារគណនេយ្យដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងដោយជោគជ័យដោយទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកចូលរួមចំនួនជិត៦០០នាក់។

--- ២៨ ខែតុលា ឆ្នាំ២០២២ ---







## សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី ទម្រង់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

នាថ្ងៃចន្ទ ៦ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ **វ.គ.ស.ក.** បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "**ទម្រង់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**" ដោយមានការចូលរួមពីវាគ្មិនកិត្តិយស លោក **រុណ វីរៈ** នាយកផ្នែកពន្ធនៃក្រុមហ៊ុន **Fii & Associates**។ សិក្ខាសាលានេះបានទទួលជោគជ័យ ដោយមានការចូលរួមជាច្រើនដែល មកពីសាកលវិទ្យាល័យដែលជាដៃគូរបស់ **វ.គ.ស.ក.** និងស្ថាប័នផ្សេងៗទៀត។

--- ១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ---







## វគ្គបណ្តុះបណ្តាលស្តីពី CIFRS 15: Revenue from Contracts with Customers

វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(**វ.គ.ស.ក.**)មានការសហការជាមួយ **KPMG Cambodia Ltd** ដោយបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**CIFRS 15: Revenue from Contracts with Customers**" នៅថ្ងៃអង្គារ ទី ៦ ខែធ្នូ ឆ្នាំ ២០២២ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ១១:៣០ ព្រឹក។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត(CPD) សម្រាប់សមាជិកKICPAA និងទីផ្សារគណនេយ្យដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងដោយជោគជ័យដោយទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកចូលរួមចំនួនជិត៦០០នាក់។

--- ៦ ខែធ្នូ ឆ្នាំ២០២២ ---






# ៣ អនុស្សរណៈនៃការយោគយល់គ្នា

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA)

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.** និង **វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ** (IFA) លើកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យដែលប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ២:០០ រសៀល នៅបន្ទប់ប្រជុំវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។

--- ៦ ខែមករា ឆ្នាំ២០២២ ---









## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និងសាកលវិទ្យាល័យ បៀលប្រាយ

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.** និង **សាកលវិទ្យាល័យ បៀលប្រាយ** លើកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១០:០០ ព្រឹក នៅបន្ទប់ប្រជុំសាកលវិទ្យាល័យ បៀលប្រាយ។

--- ២០ ខែមករា ឆ្នាំ២០២២ ---







# ពិធីចុះអនុស្សរណៈនៃការយោគយល់ ស្តីពីការចុះកម្មសិក្សារបស់និស្សិតក្នុងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការចុះកម្មសិក្សារបស់និស្សិតក្នុងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ។ ខ្លឹមសារនៃអនុស្សរណៈនេះមានគោលបំណងផ្តល់ឱកាសជូននិស្សិតដែលកំពុងសិក្សាកម្មវិធីបច្ចេកទេសគណនេយ្យ (ATQ) របស់ **វ.គ.ស.ក.** ចុះកម្មសិក្សាផ្ទាល់ជាមួយ **ក្រុមហ៊ុន** ដែលបានចុះអនុស្សរណៈនេះ។ បន្ថែមលើខ្លឹមសារនេះ ក្រុមហ៊ុន នឹងជំរុញលើកទឹកចិត្តឱ្យបុគ្គលិករបស់ខ្លួនចូលរួមសិក្សា និងប្រឡងក្នុងកម្មវិធីបច្ចេកទេសគណនេយ្យ។ កម្មវិធីសិក្សានេះនឹងក្លាយជាផ្នែកមួយនៃការពង្រឹងសមត្ថភាព និងផលិតភាពបុគ្គលិកកាន់តែប្រសើរជាងមុន។




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន បញ្ញើ ហ្វាញ្ញថេក ឯ.ក**
--- ១២ ខែឧសភា ឆ្នាំ២០២២ ---




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន ខេ ហ្វ៊ីហ្វេសិនណល អ៊ីខោនថិន**
--- ១២ ខែឧសភា ឆ្នាំ២០២២ ---




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.**
និង **ក្រុមហ៊ុន អិលអរអេស ហេនឌើសិន (ខេមបូឌា)**
--- ១២ ខែឧសភា ឆ្នាំ២០២២ ---




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន 3អេស ខនសាល់ធីង ឯ.ក**
--- ២០ ខែឧសភា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុនអេហ្វអាយអាយ & អឹសូស៊ីអេត**

--- ២ ខែមិថុនា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.**
និង **ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**

--- ២ ខែមិថុនា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.**
និង **ក្រុមហ៊ុនអេក្សឹស វីអេសឌីខេ & ផាតនើរ ឯ.ក**

--- ១៥ ខែមិថុនា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

--- ៤ ខែកក្កដា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង **វ.គ.ស.ក.**
និង **ក្រុមហ៊ុនអាល់នីសុន អឌីធីន អេន ខនសាល់ធីង**

--- ៤ ខែកក្កដា ឆ្នាំ២០២២ ---



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន អេធីអេភី & ផាតនើរ ឯ.ក**

--- ៤ ខែកក្កដា ឆ្នាំ២០២២ ---




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង
**វ.គ.ស.ក.** និង **ក្រុមហ៊ុន ដូណាស្ទ & ខមតេនី អិលធីឌី**
--- ៥ ខែតុលា ឆ្នាំ២០២២ ---

## ៤ កិច្ចសហការនិងការចូលរួមជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិនានា

**វ.គ.ស.ក.** បានចូលរួមក្នុងសកម្មនានា ជាមួយស្ថាប័នជាតិ និងអន្តរជាតិដូចជា÷

### និយ័តករគណនេយ្យនិងសវនកម្ម

| | |
|---|---|
| ១ | បានចូលរួមក្នុងកិច្ចប្រជុំរបស់និយ័តករគណនេយ្យនិងសវនកម្ម ស្តីពី ការពិគ្រោះយោបល់លើយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ |
| ២ | បានចូលរួមក្នុងកិច្ចប្រជុំលើកទី៤របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា (Monitoring Committee) កាលពីថ្ងៃទី២២ ខែមិថុនា ស្តីពី (១) ការធ្វើបច្ចុប្បន្នភាព Assessment Statement របស់ប្រទេសកម្ពុជានិងការរួមចំណែករបស់កម្ពុជាទៅក្នុង ASEAN CPA Coordination Committee (ACPACC) (២) យន្តការអនុវត្ត និតិវិធីក្នុងការអនុម័ត ASEAN CPA និងការបំលែងគណនេយ្យករបរទេសទៅជា Registered Foreign Professional Accountant (RFPA) (៣) កិច្ចសហការរវាង ន.គ.ស./វ.គ.ស.ក. ជាមួយនឹងក្រសួងពាណិជ្ជកម្ម និងក្រសួងស្ថាប័នដទៃទៀតក្នុងការអនុវត្ត MRA on Accountancy |
| ៣ | ចូលរួមកិច្ចប្រជុំជាមួយនិយ័តករគណនេយ្យនិងសវនកម្មស្តីពីការធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យគណនេយ្យ និងសវនកម្ម កាលពីថ្ងៃទី១៦ ខែកញ្ញា នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤ | ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ (NRA) សម្រាប់ “Module 2: ភាពងាយរងគ្រោះថ្នាក់ជាតិ (National Vulnerability)” ចំពោះអថេរលេខ១៦: ភាពអាចរកបាននៃសវនកម្មឯករាជ្យ (Availability of independent audit) |

## ASEAN Federation of Accountants (AFA)

| | |
|---|---|
| ១ | ចូលរួម AFA IFAC SMO Workshop on SMO 5 - IPSAS នៅខែមេសា ឆ្នាំ២០២២តាមរយៈ Online |
| ២ | ចូលរួមប្រជុំ 134th AFA Council Meeting on 26th May 2022 នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ |
| ៣ | ចូលរួម IFAC-AFA SMO Workshop ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ |
| ៤ | ចូលរួមប្រជុំ 135th AFA council នៅខែវិច្ឆិកា ឆ្នាំ២០២២ |

## International Federation of Accountants (IFAC)

| | |
|---|---|
| ១ | ចូលរួម webinar ដែលរៀបចំឡើងដោយ IFAC & Jeju Group Presents Update: Sate of Play - Reporting and Assurance of Sustainability Information កាលពីថ្ងៃទី២០ កញ្ញា |
| ២ | ចូលរួម IFAC-CAPA webinar on Global Sustainability Dialogue ថ្ងៃទី២៩ ខែកញ្ញា |
| ៣ | បានធ្វើបច្ចុប្បន្នភាពនៃព័ត៌មានដែលពាក់ព័ន្ធនឹងវឌ្ឍនភាព **វ.គ.ស.ក.** និងចូលរួមប្រជុំការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពវ.គ.ស.ក. ឆ្លើយតបនឹងSMOsរបស់ IFAC ជាមួយក្រុមការងាររបស់IFACនៅថ្ងៃទី២០ ខែតុលាតាមរយៈonline |
| ៤ | ចូលរួម 2022 IFAC-EdExchange: The future of Technology in Accounting Summit ពេលយប់ |
| ៥ | ចូលរួមក្នុង Webinar ដែលរៀបចំឡើងដោយ IFAC EdExchange: Empowering PAOs to Advance Digital Readiness, A Convocation for PAO‟s Technology and Education Directors |

## ICAEW

| | |
|---|---|
| ១ | ចូលរួម ICAEW Webinar on Fostering Agility to Combat Money Laundering and Economic Crime ថ្ងៃទី២៨ ខែកញ្ញា |

## EUROCham

| | |
|---|---|
| ១ | បានចូលរួមកម្មវិធី Eurocham Luncheon: Cambodia Start Up - SMEs Ecosystem ថ្ងៃទី១៩ ខែតុលា |

## ៥ ក្រុមការងារពន្ធដារ និងក្រុមការងារគណនេយ្យនិងសវនកម្ម

**វ.គ.ស.ក.** បានរៀបចំបង្កើតក្រុមការងារ **វ.គ.ស.ក.** (KWG- KICPAA Working Group) ដើម្បីប្រមូលព័ត៌មាន និងបញ្ហាដែលសមាជិកកំពុងប្រឈម ឬជាសំណូមពរផ្សេងៗ ដែលពាក់ព័ន្ធនឹងពន្ធដារ បញ្ជូនទៅក្រុមការងារពន្ធដារវិស័យឯកជន (TWG-Private Sector) ធ្វើការពិចារណានិងបន្តនីតិវិធីដោះស្រាយជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកគណនេយ្យនិងសវនកម្ម បញ្ជូនទៅនិយ័តករពាក់ព័ន្ធ ធ្វើការពិចារណានិងផ្តល់ជាអនុសាសន៍ ឬដំណោះស្រាយតាមការគួរ។ ក្រុមការងារនេះ បានរៀបចំបង្កើតនៅក្នុងខែវិច្ឆិកានឹងធ្វើការប្រមូលនូវបញ្ហាពីសមាជិកជារៀងរាល់ខែ ហើយពិនិត្យនិងពិចារណារៀបចំបញ្ជូនទៅ TWG និងនិយ័តករគណនេយ្យនិងសវនកម្មតាមការចាំបាច់និងការគួរ។

## ៦ ស្លាកសញ្ញាថ្មីរបស់ វ.គ.ស.ក.

ការរៀបចំបង្កើតនិងផ្លាស់ប្តូរ ស្លាកសញ្ញា ត្រាស្ងួត ត្រា ថ្មីរបស់ **វ.គ.ស.ក.** បានរួចរាល់ហើយ និងបានបញ្ជូនសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈនិយ័តករគណនេយ្យនិងសវនកម្ម បច្ចុប្បន្ន **វ.គ.ស.ក.** កំពុងរង់ចាំនិយ័តករ និងក្រសួងពាក់ព័ន្ធផ្តល់ការសម្រេចយល់ព្រម។

## ៧ ការស្ទង់មតិ អត្ថបទស្រាវជ្រាវ និងការបោះផ្សាយ

ក្នុងឆ្នាំនេះ **វ.គ.ស.ក.** បានរៀបចំធ្វើការស្ទង់មតិមួយស្តីពី “**បញ្ហាប្រឈមរបស់ក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មប្រភេទតូចនិងមធ្យម**” ដែលជាសមាជិករបស់ **វ.គ.ស.ក.** ក្នុងគោលបំណងស្វែងយល់បន្ថែម និងកាន់តែស៊ីជម្រៅលើរាល់បញ្ហាដែលសមាជិកបានជួបប្រទះ និងជួយរកដំណោះស្រាយ ក៏ដូចជាផ្តល់ការគាំទ្រ ដល់សមាជិកតាមដែលអាចធ្វើបាន។ បន្ថែមលើសពីនេះ **វ.គ.ស.ក.** បានចូលរួមធ្វើជាដៃគូស្រាវជ្រាវ (Research Partner) ជាមួយ IMA (Institution of Management Accountants) នឹងចាប់ផ្តើមរៀបចំធ្វើការសិក្សាស្រាវជ្រាវសាកលស្តីពីការរក្សាបុគ្គលិកឆ្នើមក្នុងវិជ្ជាជីវៈគណនេយ្យនិងហិរញ្ញវត្ថុ (Global research study on talent retention within the accounting and finance profession)។ គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះគឺដើម្បីផ្តល់ឱ្យអ្នកដឹកនាំផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ជាមួយនឹងយុទ្ធសាស្ត្ររក្សាបុគ្គលិកឆ្នើមប្រកបដោយប្រសិទ្ធភាព។ ការសិក្សាស្រាវជ្រាវនេះនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៣។

## ៨ កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

KICPAA RECOGNIZED. TRUSTED.

ICAEW

With financial support from the Russian Federation

UNDP




“ជំហានឆ្ពោះទៅកាន់អាជីពគណនេយ្យ”

– ធ្វើការប្រឡងនៅថ្ងៃនេះដើម្បីក្លាយជាអ្នកបច្ចេកទេសគណនេយ្យ !

LEARNING HUB




## អំពី វ.គ.ស.ក.

- ជាស្ថាប័នមិនស្វែងរកប្រាក់ចំនេញ និងឯករាជ្យក្នុងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែមួយគត់នៅកម្ពុជា
- បង្កើតឡើងដោយច្បាប់ និងបទប្បញ្ញតិនានា តាំងពីឆ្នាំ ២០០៣
- ដើម្បីការពារផលប្រយោជន៍សាធារណៈនិងផលប្រយោជន៍វិជ្ជាជីវៈ គ្រប់គ្រងសមាជិករបស់ខ្លួនដោយផ្តល់នូវការអភិវឌ្ឍសមត្ថភាពក្នុងវិជ្ជាជីវៈ ចូលរួមជម្រុញអនុលោមភាពនៃស្តង់ដារ ក្រមសីលធម៌វិជ្ជាជីវៈ វិធាននិងបទប្បញ្ញតិនានា ព្រមទាំងអភិវឌ្ឍ និងគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យជំនាញ។

## អំពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យថ្មី (ATQ)

ត្រូវបានអភិវឌ្ឍឡើងដោយ KICPAA ក្រោមការគាំទ្របច្ចេកទេសពី ICAEW និងឧបត្ថម្ភធនពី Russian Federation និង UNDP Cambodia ។ ATQ អាចជួយឱ្យនិស្សិតចំណាយពេលខ្លីក្នុងការសិក្សា និងអាចសិក្សានៅនឹងកន្លែងរបស់គេផ្ទាល់។ និស្សិតគ្រប់ទីកន្លែងនៅកម្ពុជាអាចសិក្សាជាមួយស្ថាប័នបណ្តុះបណ្តាលដែលជាដៃគូ ឬដោយខ្លួនឯងតាមរយៈកម្មវិធី LEARNING HUB ។

ATQ គឺជាកម្មវិធីប្រឡងសម្រាប់ការទទួលស្គាល់ជំនាញគណនេយ្យកម្រិតបច្ចេកទេស។ ក្រោយពេលប្រឡងជាប់ពីរមុខវិជ្ជាដំបូងនិស្សិតនឹងក្លាយជាអ្នកកាន់បញ្ជីគណនេយ្យប្រកបដោយសមត្ថភាព ដែលមានតម្រូវការទីផ្សារការងារខ្ពស់។

## ហេតុអ្វីគួរជ្រើសរើស ATQ?

- ជាកម្មវិធីគណនេយ្យជំនាញដែលមានការទទួលស្គាល់
- អាចបត់បែនក្នុងការសិក្សា
  - សិក្សាដោយខ្លួនឯងតាមរយៈកម្មវិធី LEARNING HUB
  - សិក្សាជាមួយស្ថាប័នបណ្តុះបណ្តាលដែលជាដៃគូនៅកម្ពុជា
- អាចចុះកម្មសិក្សាជាមួយក្រុមហ៊ុនដែលជាសមាជិករបស់ KICPAA
- បន្ថែមគុណតម្លៃសម្រាប់អាជីពគណនេយ្យរបស់អ្នក
- មានឱកាសការងារខ្ពស់

## ឆ្ពោះទៅថ្ងៃអនាគត

- សុខដុមរមនីយកម្មនៃកម្មវិធីសិក្សាគណនេយ្យទូទាំងប្រទេសដែលអាចពង្រឹងដល់ប្រព័ន្ធអប់រំនៅកម្ពុជា
- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនដើម្បីត្រៀមខ្លួនក្នុងការប្រកបអាជីពនេះ
- ផ្តល់នូវសេវាកម្មគណនេយ្យប្រកបដោយទំនុកចិត្តនិងប្រកបដោយវិជ្ជាជីវៈដែលជួយដល់សេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅពេលអនាគត

## ការណែនាំពីកម្មវិធី LEARNING HUB!

- **រៀនតាមប្រព័ន្ធអនឡាញ គ្រប់ពេលវេលា គ្រប់ទីកន្លែង**
- **រៀនជាភាសាខ្មែរ ឬអង់គ្លេស**
- **មានបញ្ចូល នូវកម្មវិធីសិក្សា និងតេស្តសាកល្បងផ្សេងៗ**

## ចាប់ផ្តើមការសិក្សាជាមួយយើង

០១ ចុះឈ្មោះជាសមាជិក KICPAA
០២ ចាប់ផ្តើមមុខវិជ្ជាមុនដំបូង
០៣ អានសៀវភៅពុម្ព ធ្វើតេស្តសាកល្បង និងប្រឡងសាកល្បង
០៤ ជ្រើសរើសការប្រឡងបញ្ចប់
០៥ ទទួលបានវិញ្ញាបនបត្រមួយនៅពេលដែលអ្នកប្រឡងជាប់ពីរមុខវិជ្ជា
០៦ បំពេញការងារ ឬការចុះកម្មសិក្សា
០៧ ក្លាយជាអ្នកបច្ចេកទេសគណនេយ្យ

## កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

**កម្រិតមូលដ្ឋានគ្រឹះ**

**ភាគ ១**
អ្នកកាន់បញ្ជីគណនេយ្យ ទទួលស្គាល់ដោយ វ.គ.ស.ក.

- **TQ1:** ការកាន់បញ្ជីគណនេយ្យ
- **TQ2:** បច្ចេកទេសកុំព្យូទ័រ និងកម្មវិធីសូហ្វវែរគណនេយ្យ

**ភាគ ២**
គណនេយ្យករទទួលបន្ទុកថ្លៃដើម ទទួលស្គាល់ដោយ វ.គ.ស.ក.

- **TQ3:** ការសិក្សាអំពីការគណនាថ្លៃដើម
- **TQ4:** ការសិក្សាអំពីអាជីវកម្ម

**កម្រិតបច្ចេកទេស**

**ភាគ ៣**
គណនេយ្យករទទួលបន្ទុករៀបចំរបាយការណ៍ ទទួលស្គាល់ដោយ វ.គ.ស.ក.

- **TQ5:** ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- **TQ6:** គណនេយ្យសម្រាប់ការគ្រប់គ្រង

**ភាគ ៤**
មន្ត្រីទទួលបន្ទុកផ្នែកច្បាប់និងពន្ធដារ ទទួលស្គាល់ដោយ វ.គ.ស.ក.

- **TQ7:** ពន្ធដារកម្ពុជា និងការអនុវត្ត
- **TQ8:** នីតិក្រុមហ៊ុន និងអាជីវកម្មកម្ពុជា

8th Floor, VTRUST Tower, St.169, Sangkat Veal Vong, Khan 7 Makara, Phnom Penh. | +855 23 23 17 07 | education@kicpaa.org | www.kicpaa.org


DOWNLOAD OUR NEW
KICPAA APP
KICPAA
RECOGNIZED. TRUSTED.
© 2021 KICPAA.
Senior Audit Associate
KPMG Full Time Phnom Penh December 31, 2021
My Account
ATQ-Education
Membership
Law & Regulation
Training & Events
News
Membership Assesment
Career Support
Learning Resource
ATQ Program
WELCOME!
Username or Email
Password
LOG IN
Forgot Password?
New to KICPAA Apps? Sign Up
DOWNLOAD IT TODAY ON
Download on the App Store
GET IT ON Google Play
Study online anytime anywhere | Khmer or English available

# សមាជិកភាព

# សមាជិកជាប្រភេទក្រុមហ៊ុន

## ១ សមាជិកក្រុមហ៊ុនសេវាគណនេយ្យ

| ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|
| 3អេស ខនសាល់ធីង ឯ.ក | 087 552 035 | #110, Street 06A, Thmey Village, Dangkor, Phnom Penh, Cambodia. |
| អាខ្មែម (ខេមបូឌា) ឯ.ក | 023 215 960 | #39c, Street318, Phum 2, Samgkat Toul Svay Prey I, Khan Boeng Keng Kang, PhnomPenh, Cambodia. |
| ឌី អេ អេស & ផាតនើរ ឯ.ក | 012 25 24 13 | #6 Street 474, 7 Village, Boeung Trabeic, Chamkar Mon, Phnom Penh. |
| ហាន់ហ្គោ ស៊ូជី តាក់ & អឹខោនធីង (ខេមបូឌា) | 023 998 190<br>010 872 999 | Building #216, Icon Room 39E1, Norodom Blvd, Sangkat Tonle Basac,Khan Chamkamon, Phnom Penh, Cambodia |
| អាយ គ្លោខល | 023 964 405 | #445 Phnom Penh Tower, 13 Floor, Monivong Blvd, Sangkat Boeung Pralit, Khan 7 Makara, Phnom Penh. |
| ឡា ប៉េ ខេអេច អឌីតធីង & ខនសាល់ធីង ឯ.ក | 070 496 666 | National Road No.6 Phum Banteay Chas, Sangkat Sla Kram Siem Reap City,Siem Reap Province. |
| ស្កាយលីមីធីត អឹខោនធីង (ខេមបូឌា) ខូ អិលធីឌី | 092 786 541<br>092 786 540 | B-Ray Tower (8th Floor), No.166, Norodom Blvd, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh |
| វីឌីបី ឡូយ លីមីធីត | 023 964 430 | No.33, St.294 Corner St.29, Phum 4, Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia |

## ២ សមាជិកក្រុមហ៊ុនសេវាគណនេយ្យ និងសវនកម្ម

| ឈ្មោះក្រុមហ៊ុន | ទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|
| អ៊ែតវ៉ាន់ស៍ ហ្វ្រេន ហ្វ៊រម៉ូឡា ឯ.ក | 085 368 888 | #180, Borey Chip Mong Land, Street P13, Sangkat Phnom Penh Tmey, Khan Sen Sok, Phnom Penh, Cambodia. |
| អាល់នីសុន អឌីធីង អេន ខនសាល់ធីង | 023 222 123<br>088 77 66 865 | # 54, Street 352,  Sangkat Boeung Keng Kong I, Khan Sangkat Boeung, Phnom Penh, Cambodia. |
| អ៊ែមភល & ផាតនើរ (ខេមបូឌា) ឯ.ក | 0I6 59 58 56 | House/Building No.26 (2nd floor), Street/Road No.610,20, Boeng Kak Ti Pir, Tuol Kouk, Phnom Penh, Cambodia |
| អេនឌ្រូ & ហ្វីលីព អឹខោនធីង (អេ & ភី អឹខោនធីង) | 023 964 999 | #9E, St 608, Boeung Kork 2, Toul Kork, Phnom Penh, Cambodia |
| អឹផឡូ អ៊ិនវេសម៉ិន & ខនសាល់ធីង ឯ.ក | 081 288 858 | #120ZB, St. 438, Phum 04, Sangkat Toul Tompoung 2, Khan Chamkar Mon, Phnom Penh, Cambodia |
| អេ ភី វី (ខេមបូឌា) ខូ អិលធីឌី | 078 666 001<br>023 238 818 | #26B-95A-95B, Street 320, Sangkat Beoun Keng Kang Ill, Khan Beoung Keng Keng, Phnom Penh. |
| អេធី & អាសូស៊ីអេត | 023 212 616<br>012 92 31 75 | 39C, St. 155, Toul Tompung I, Khan Chamkarmon, Phnom Penh |
| អេធីអេភី & ផាតនើរ ឯ.ក | 023 23 38 68<br>016 646 344 | #531, St.128, Phum 7, Sangkat Psadepo 1, Khan Toul Kork, Phnom Penh, Cambodia |
| អាត្លាស ខនសាល់ធីង ឯ.ក | 089 666 383<br>092247555 | No. 08 Street P-27, Borey Peng Huoth The Star Platinum Polaris II, Veal Sbov Commune, Chbar Ampov District, Phnom Penh, Cambodia. |

| | | |
|---|---|---|
| អេ-អិចសីឡិន ខនសាល់ធេនស៊ី ឯ.ក | 016 268 689 | #14, St. 02, sangkat Toek Laak III, Khan Toul Kork, Pnhom Penh, Cambodia |
| បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក | 023 987100 | #87B, St 294,Sangkat Boeung Keng Kang 1, Khan Chamkar Mon, Phnom Penh, Cambodia |
| ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | 023 218 128 | Suit 28, Hotel Cambodiana, 313 Preah Sisowath Quay, Chaktomuk, Duan Penh. |
| ប៊ីជី អាសូស៊ីអ៊ីត | 023 218 426 | Unit S13A02, Diamond Twin Tower, Street, Sopheak Mongkol, Tonle Bassac, Phnom Penh. |
| ប៊ូ ឆាធើរ អីខោនថិន អេន អឌីតធ័រ ឯ.ក | 077 691 008 | 1st Floor, CPL Building, Street 348 corner street 205, Sangkat Toul Svay Prey II, Khan Chomkar Morn, Phnom Penh. |
| ខេម អីខោនធីង & ថាក សឺវីស ឯ.ក | 089 777 589 | #3D, Street 416, Sangkat Tumnup Teuk, Khan Chamkar Morn, Phnom Penh, Cambodia |
| ស៊ី អេច អ៊ឹង អាសូស៊ីអេត ភីធីអ៊ី អិលធីឌី | (65)96 694 540 | No.19, St730, Sangkat Psar Tko, Khan Chamkarmon, Phnom Penh, Cambodia. |
| ចន្ទ & អឹសូស៊ីអេត | 095 555 188 | 7 floor (Amret Building), #80, Street 315, Beoung kak 2, Toul Kork, Phnom Penh, Kingdom of Cambodia. |
| ក្រូវ (ខេអេច) ឯ.ក | 023 216 717<br>016 507 655 | Unit4B, 4th Floor, K1 Building #48, Mao Tse Toung Blvd, St. 245, Toul Tom Poung 2, Phnom Penh |
| ឌី ឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី | 023 963 777 | Floor 8, Unit 8, #66, Monivong Blvd, Sangkat Voat Phnom, Khan Doun Penh, Phnom Penh, Cambodia. |
| ដូណាស្វ & ខមភេនី អិលធីឌី | 023 997 830<br>012 896 486 | M Floor, Room MA1, CDX Residence Building, # 53, St. 446, Toul Tompoung I, Khan Chamkarmon, Phnom Penh |
| អ៊ីស្ត វីង អឌីធីង និង ខនសាល់ធីង | 061 566 667 | #108AB, Moa Setoung Blvd (245), Phum 2, Sangkat Toul Tompong Ti 2, Khan Chamkarmon, Phnom Penh, Cambodia. |
| អេក្វីស វីអេសឌីខេ & ផាតនើរ ឯ.ក | 089 520 005 | #17, St.135 (Corner 500), Phsar Derm Thkov, Phnom Penh, Cambodia |
| អឹនស្ទ័ អែន យ៉ាំង (ខេមបូឌា) | 023 217 824 | 5th Floor, Emerald Buidling, #64 Norodom Blvd Corner St. 178, Sangkat Chey Chumneah, Khan Daun Penh, Cambodia. |
| ហ្វីដេស សឺវីស (ខេមបូឌា) លីមីធីត | 023 217 307<br>012 880 920 | 3 Street 240, Sangkat Chaktomuk, Khan Daun Penh, Phnom Penh, Cambodia |
| អេហ្វអាយអាយ &អឹសូស៊ីអេត | 096 5551455<br>023 555 1455 | C7 Building, Street Vimean Ahha, Kien Klaing Village, Sangkat Chroy Changvar, Khan Chroy Changvar, Phnom |
| ហ្វរមី & ផាតនើរ ឯ.ក | 023 926 999<br>070 465 777 | #12, St.348, Village 4, Toul Svay Prey 1 Commune, Chamkarmon, District, Phnom Penh |
| ហ្វូណាន ខនសាល់ធីង ឯ.ក | 069 923 337 | PPIU Building, #36, 9th Floor, Street 169, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Kingdom of Cambodia. |
| ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | 023 966 520<br>010 58 59 60 | 20th Floor, Canadia Tower, Phnom Penh, Cambodia. |
| អេចធី & ភី ផាតនើរ ឯ.ក | 023 231 236 | Unit G33A02B, Floor 33A, GIA Tower, Koh Pich,Phnom Penh, Kingdom of Cambodia. |
| ខេ ប្រីហ្វេសិនណល អីខោនថិន | 099 554 445 | 5th Floors, CPL Building, Sangkat Toul Svay Prey II, Khan Chamkarmon, Phnom Penh, Cambodia |
| ខេ ភី អឹម ជី ខេមបូឌា | 017 666 537<br>078 786 680 | 35th Floor, GIA Tower, Sopheak Mongkul Street, Diamond Island, Sangkat Tonle Bassac, Khan Chomkarmon, Phnom Penh,Kingdom of Cambodia. |
| ឡូចន្ទ & ខូ (ខេមបូឌា) ឯ.ក | 023 211 541<br>070 228 907 | 6th Floor, Office No. 3, The Emerald Building, Preah Norodom corner 178, Khan Daun Penh, Phnom Penh, Cambodia |

| | | |
|---|---|---|
| អិលអអេស ហេនឌើសិន (ខេមបូឌា) | 092 382 555 | Unit 121, 1th Floor, Phnom Penh Center, Sothearos Blvd, Tonle Basac, Khan Chamkamon, Phnom Penh, Cambodia. |
| ម៉ូរីសុនកាក់ អិមខេអេ អឌីត-អឹខោនធីង ឯ.ក | 023 218 994 | No.10, Street 500, Sangkat Phar Doeum Thkov, Phnom Penh. |
| អិន អេ អេស | 012 786 971 | #431 (7 Floor), St 230, Teuk Laok 3, Khan Toul Kork, Phnom Penh, Cambodia. |
| ញូ សាញ ខនសាល់ធីង ឯ.ក | 089 792 795 | 445 Phnom Penh Tower, Monivong Blvd, Boeung Prolit, 7 Makara, Phnom Penh, Cambodia |
| អិនអិនធី ឆាតធើរ អាខោន ឯ.ក | 093 566 691 | #3C2Penh, Street 516A, Group 1, Sangkat Boeung Kak 1, Khan Toul Kork, Phnom Penh |
| ភី អេ ធី ប្រឹហ្វេសិនណល លីមីធីត | 023 967 156<br>098 951 156 | Olympia City, Building C7, 8th Floor, Room 817-818, St. Oknha Tepphon (182) Corner (161), Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia. |
| ផេក ខនសាល់ធីង ឯ.ក | 017 666 078 | Borey Peng Hout Residence, #41, Room P1, Road R02, Boeung Chhuk, Sangkat Niroth, Chba Ampov, Phnom Penh, Cambodia. |
| ភីខេអេហ្វ ខូវេណិនថ៌ ឯ.ក | 023 884 138<br>081 686 226 | No. 689A, Kampuchea Krom Boulevard (128), Sangkat Toek Laak I, Khan Toul Kork, Phnom Penh, Cambodia |
| ប្រាយវ៉ែតធ័រហោវខូភើស៍ (ខេមបូឌា) | 023 860 606<br>012 510 111 | #58 Preah Sihanouk Blvd. Khan Chamkarmon, Phnom Penh, Cambodia |
| ខ្វនថឹម & ស្តេកត្រឹម ឯ.ក | 012 228 069 | #10, VTrust Mittapheap Building, Unit 1FC2, St 109, Sangkat Mittapheap, Khan 7 Makara, Phnom Penh |
| រីចឆ៍ & ផាតនើរ | 023 230 333<br>011 210 348 | #2283-2282-2399, Ground Floor-room G01 1.01 and Second Floor-Room 2.01, St. 1970, Sangkat Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh , Cambodia. |
| រីនដា អិល អិល ខេ ជី (ខេមបូឌា) | 023 222 182 | Room 2255 of #54, Street 352, S/K Boeung Keng Kong I, Khan Beoung Keng Kang, Phnom Penh, Cambodia |
| រ៉ូស្វូខូ លីមីធីត | 012 78 97 65<br>023 212 280 | No.8, St.492, Sangkat Phar Deoum Thkov, Chamkarmon, Phnom Penh, Cambodia |
| សំរិទ្ធិ អឹខោនធីង អេន មេនេចម៉ិន ឯ.ក | 095 333 799 | Rd Keo Chenda, Mekong View Tower 6, Sangkat Chroy Changvar, Khan Chroy Changvar, Phnom Penh |
| អេសស៊ីអេស គ្លូប៊ល ខនសាល់ធីង (ខេមបូឌា) | 023 901 125<br>010 294 523 | #515 1st floor (room 103), Monivong Blvd, Sangkat Beong Keng Kang II, Khan Chamkarmon Pnhom Penh, Cambodia. |
| អេស អិម គ្លូប៊ល អឹខោនធីង & ខនសាល់ធីង | 023 990 853 | #53, Monivong Blvd, Sangkat Srah Chock, Khan Daun Penh, Phnom Penh., Cambodia |
| សឡឹម៉ិន អឹខោនធីង ខនសាល់ធីង | 023 99 88 44<br>012 241 000 | #148 K1 Building, 10th Floor, Mao Tse Toung Blvd., Sangkat Toul Tumpoung 2, Khan Chamkamorn, Phnom Penh. |
| ថៃ អេន ឡោ មេនេចម៉ិន ខនសាល់ធេន ឯ.ក | 023 882 152<br>012 661 166 | #949, Phum Trung Moan, Sangkat O Bek Kaorm, Khan Sen Sok, Phnom Penh, Cambodia |
| ទ្រីណឺធី ប្រឹហ្វេសិនណល | 012 668 846 | #77, St. 1011, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. |
| វីប៊ីធី អេន ផាតនើរ ឯ.ក | 012 268 816 | 76E0, Street 20, Trapeang Thloeung, Sangkat Chom Chao, Khan Por Sen Chey, Phnom Penh, Cambodia |
| វី ឆាធើរ អឹខោនថិន | 023 985 468 | Phnom Penh Centre, Room 482, Floor 4, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh. |
| វ៉ូរី អេខោនធីង (ខេមបូឌា) ឯ.ក | 023 223 878 | IOC Center GF, No 254, Monivong Blvd, Phnom Penh, Cambodia |
| យ៉ុងអាន អ៊ិនធើណេសិនណល ខនសាល់ធីង ឯ.ក | 088 716 2158 | Room No.907, Floor 9 of Carnation Building, Path Road, Phum Tumnob1, Sangkat Phnom Penh Thmey, Khan Sensok, Phnom Penh, cambodia |

# សមាជិកជាប្រភេទបុគ្គល

- សមាជិកកិត្តិយស
- សមាជិកចូលរួម
- សមាជិកសកម្ម
- សមាជិកសមាគត



**សូមចុចលើ link ខាងក្រោមសម្រាប់**
**ព័ត៌មានលម្អិតបន្ថែម**

**https://www.kicpaa.org/membership-2/members-type/**

# ដំណើរការនៃការស្នើសុំសមាជិកភាព



### ការសាកសួរព័ត៌មាន

ទាក់ទងមកមន្ត្រីផ្នែកសមាជិកភាព ឬ ចូលទៅកាន់គេហទំព័រ (www.kicpaa.org) ដើម្បីទទួលបានព័ត៌មាន និងពាក្យស្នើសុំ

?

Scan to learn more!
- Requirements
- Application forms
- Member fee
- CPD policy



### ការដាក់ពាក្យ

បំពេញនិងដាក់ពាក្យស្នើសុំដោយភ្ជាប់ជាមួយ ឯកសារតម្រូវនានា មកកាន់ ការិយាល័យ វ.គ.ស.ក.

8th Floor, VTRUST Tower, St 169, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia.



### ការបង់ថ្លៃដាក់ពាក្យ

ក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ មន្ត្រី វ.គ.ស.ក. នឹងផ្តល់ព័ត៌មានជូនបេក្ខជនវិញ ហើយ វ.គ.ស.ក. តម្រូវឱ្យអ្នកបង់ថ្លៃពាក្យស្នើសុំសមាជិកភាព។

$



### ការផ្ទៀងផ្ទាត់ព័ត៌មាន

វ.គ.ស.ក. ត្រូវការរយៈពេលប្រមាណ ១ ខែ ឬច្រើនជាងនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន។



### ការប្រកាសលទ្ធផល

បន្ទាប់ពីការផ្ទៀងផ្ទាត់ត្រូវបានបញ្ចប់ ពាក្យស្នើសុំរបស់អ្នកនឹងត្រូវបានវាយតម្លៃដោយគណៈកម្មការចុះឈ្មោះ និងសមាជិកភាពហើយលទ្ធផលផ្លូវការនឹងត្រូវបានផ្ញើជូនអ្នកតាមរយៈអ៊ីមែល។

**ចំណាំ÷** ប្រសិនបើអ្នកមានចម្ងល់អំពីដំណើរការចុះឈ្មោះ ឬឯកសារដែលត្រូវការ សូមធ្វើការទាក់ទងមកកាន់មន្ត្រីសមាជិកភាព KICPAA ដែលតែងតែស្វាគមន៍ក្នុងការប្រឹក្សាជាមួយអ្នកជានិច្ច។

**H/P:** 023 23 17 07 | ទូរស័ព្ទ÷ 077 24 17 07 | អ៊ីមែល÷ membership@kicpaa.org

## ហេតុអ្វីត្រូវក្លាយជាសមាជិក វ.គ.ស.ក.?

1. ជាសមាជិក វ.គ.ស.ក. អ្នកអាចស្នើសុំអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)
2. មានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនិយ័តករគណនេយ្យនិងសវនកម្ម
3. មានកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD)
4. ទទួលបានការបញ្ចុះតម្លៃលើការចូលរួមក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងទៀតដែលរៀបចំដោយ វ.គ.ស.ក.
5. ទទួលបានបច្ចុប្បន្នកម្មនៃបញ្ហាប្រឈមនានា ដើម្បីពង្រឹងអង្គភាពរបស់អ្នកឱ្យកាន់តែប្រសើរឡើងនាពេលអនាគត
6. ពង្រីកនិងពង្រឹងនូវទំនាក់ទំនងជាមួយសមាជិកផ្សេងៗ និយ័តករសំខាន់ៗ និងភាគីពាក់ព័ន្ធនានា
7. អ្នកនឹងទទួលបានព័ត៌មានថ្មីៗស្តីពីការកែសម្រួលបទប្បញ្ញត្តិ និងបញ្ហាបច្ចេកទេសនានា ដែលប៉ះពាល់ដល់កាតព្វកិច្ចផ្នែកច្បាប់ អនុលោមភាព និងស្តង់ដានានាតាមរយៈការចែករំលែកអត្ថបទ វីដេអូ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ វ.គ.ស.ក.ជាដើម
8. អតិរេកដែលបានមកពីវិភាគទាន (ថ្លៃសមាជិកភាព) នឹងត្រូវបានប្រើប្រាស់ជាប្រយោជន៍សង្គម និងគាំទ្រដល់វគ្គបណ្តុះបណ្តាលនានាដើម្បីការអភិវឌ្ឍនៃវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា

## កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត

នៅ វ.គ.ស.ក. យើងរៀបចំ និងផ្តល់ជូននូវ ទិន្នន័យរបាយការណ៍ ធនធាន និងឧបករណ៍វិជ្ជាជីវៈគណនេយ្យ និងសវនកម្មផ្សេងៗជារៀងរាល់ឆ្នាំសម្រាប់សមាជិករបស់យើងដើម្បីបន្តអភិវឌ្ឍចំណេះដឹង និងវិជ្ជាជីវៈ គណនេយ្យនិង សវនកម្មរបស់ពួកគេ។

ក្នុងនាមជាសមាជិកមួយក្នុងចំណោមសមាជិកដែលត្រូវបានទទួលស្គាល់នៃសហព័ន្ធគណនេយ្យករអន្តរជាតិ និងសហព័ន្ធគណនេយ្យករអាស៊ាន វ.គ.ស.ក. មានសិទ្ធិទទួលបានការយល់ដឹង ទិន្នន័យរបាយការណ៍ ធនធាន និងសិក្ខាសាលាយ៉ាងច្រើន។

ដូចនៅឆ្នាំ ២០២១ វាជារឿងអកុសលដែល វ.គ.ស.ក. មិនអាចរៀបចំការបណ្តុះបណ្តាល ក្នុងថ្នាក់រៀនផ្ទាល់បាន ប៉ុន្តែយើងមិនដែលខកខានក្នុងការផ្តល់ជូនសមាជិករបស់យើងនូវ ឱកាស ឬវេទិកាសម្រាប់ បន្តការអភិវឌ្ឍចំណេះដឹង អំពីវិជ្ជាជីវៈគណនេយ្យនោះទេ។ វ.គ.ស.ក. បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង ប្រហែលជាង ២០ ប្រធានបទ ជាពិសេសការធ្វើបច្ចុប្បន្នភាពនៃស្តង់ដារគណនេយ្យ។ វ.គ.ស.ក. ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់សមាជិករបស់យើងទៅកាន់ចំណេះដឹងប្រកបដោយធនធានបំផុត និងសំឡេងនាំមុខគេពីអ្នកជំនាញធុរកិច្ចពិភពលោក។

ដូចគ្នានេះផងដែរ វ.គ.ស.ក. មានកិត្តិយសក្នុងការប្រកាសថាយើងនឹងផ្តល់ឱ្យសមាជិករបស់យើងនូវអត្ថប្រយោជន៍បន្ថែមទៀតតាមរយៈកម្មវិធី KICPAA CPD ។ យើងបានរៀបចំផែនការបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទជាច្រើនសម្រាប់ឆ្នាំ ២០២២។ ដូច្នេះ បុគ្គលដែលមានចំណាប់អារម្មណ៍អាចពិនិត្យមើលតារាងកាលវិភាគ កម្មវិធី KICPAA CPD និងកក់កាលវិភាគដើម្បីចូលរួមជាមួយយើង។

**Website** | **Telegram Channel** | **Facebook Page** | **KICPAA App**

Download on the App Store

GET IT ON Google Play

**For any inquiries on Membership Requirement, please kindly contact us at:**

**Tel:** 077 241 707

**Email:** membership@kicpaa.org

**For any inquiries on ATQ Program, please kindly contact us at:**

**Tel:** 017 493 140

**Email:** education@kicpaa.org

# កាលវិភាគសម្រាប់កម្មវិធីបណ្តុះបណ្តាលរបស់ វ.គ.ស.ក. ក្នុងឆ្នាំ២០២៣



## CALENDAR 2023

| Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | A | | | | | | | |
| | | | | | B | | | | | | |
| | | | | | | C | | | | | |
| | | | | | | | D | | | | |
| | | | | | | | | E | | | |
| | | | | | | | | | F | | |
| | | | | | | | | | | G | |
| | | | | | | | | | | | H |

| Noted | No | Topic |
|---|---|---|
| A | 1 | **Webinar: CIFRS 16**<br>**Date:** 11 May 2023 \| **Time:** 9:00am - 11:30am \| **CPD:** 2.5 hours \| **Venue:** Zoom |
| B | 2 | **Webinar: Managing Finacial Distress: Stabilization, Turnaround and Restructuring**<br>**Date:** 14 June 2023 \| **Time:** 9:00am - 12:00pm \| **CPD:** 3 hours \| **Venue:** Zoom |
| | 3 | **20th (Annual General Meeting (AGM)**<br>**Date:** 30 June 2023 \| **Time:** 3:00pm - 9:00pm \| **CPD:** 2 hours \| **Venue:** Sokha Pnhom Penh Hotel & Residence |
| C | 4 | **Webinar: Tax on E-commerce**<br>**Date:** 14 July 2023 \| **Time:** 9:30am - 11:30am \| **CPD:** TBC \| **Venue:** Zoom |
| | 5 | **Webinar: Tax on employee shares option scheme**<br>**Date:** 21 July 2023 \| **Time:** 9:30am - 11:30am \| **CPD:** 2 hours \| **Venue:** Zoom |
| D | 6 | **Webinar: CIFRS for SMEs**<br>**Date:** 03 August 2023 \| **Time:** TBC \| **CPD:** TBC \| **Venue:** Zoom |
| | 7 | **Workshop: How to Ensure full compliance with Accounting and Auditing Laws with focus on Maintaining proper accounting records**<br>**Date:** 25 August 2023 \| **Time:** 8:30am - 12:00pm \| **CPD:** 3.5 hours \| **Venue:** Physical |
| E | 8 | **Webinar: Tax updates**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 9 | **Workshop: CIFRS for SMEs: Revenue Recognition for Property Development Company**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 10 | **Workshop: CIFRS: MFI**<br>**Date :** TBA \| **Time:** TBC \| **CPD:** TBC \| **Venue:** TBC |
| | 11 | **Webinar: Analysing business internal and external environment**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |

| Noted | No | Topic |
|---|---|---|
| F | 12 | **Webinar: Differences between internal accounting and outsource accounting**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** Zoom |
| | 13 | **Webinar: CIFRS 15**<br>**Date:** TBC \| **Time:** TBC \| **CPD:** TBC \| **Venue:** Zoom |
| | 14 | **Workshop: ISQM1**<br>**Date:** TBC \| **Time:** TBC \| **CPD:** TBC \| **Venue:** Physical |
| | 15 | **Webinar: Tax Audit**<br>**Date:** TBA \| **Time:** TBC \| **CPD:** TBC \| **Venue:** TBC |
| | 16 | **Webinar: Career in accounting and bookkeeping**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** Zoom |
| | 17 | **Webinar: Accounting cycle**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** Zoom |
| G | 18 | **Workshop: Cambodian International Standards on Auditing update**<br>**Date:** 1st and 2nd \| **Time:** 2 full days \| **CPD:** TBC \| **Venue:** Physical |
| | 19 | **Webinar: CIFRSs 10**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 20 | **Webinar: Evolution of accounting**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 21 | **Webinar: VAT**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| H | 22 | **Webinar: Audit manual and enagement performance & management**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 23 | **Workshop: ISQM2**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 24 | **Webinar: CIFRS for SMEs:**<br>- Bank Sector \| - Financial Instument \| - Key Practical Approaches \| - Impairment \| - Agriculture<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 25 | **Webinar: Develop Small & Medium Practice (SMP) Digital Adoption Roadmap**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 26 | **Webinar: Facilitate & promote the technology adoption among member**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |
| | 27 | **Webinar: Publish/ share tools, insight, and guidelines related with SMP technology adoption**<br>**Date:** TBA \| **Time:** TBA \| **CPD:** TBA \| **Venue:** TBA |

The events are subjected to change without notice.

**Note:**

**TBC :** To Be Confirmed

**TBA :** To Be Accessed

ជាន់ទី ៨ អាគារ វីត្រាស់ ផ្លូវ ១៦៩ សង្កាត់ វាលវង់
ខណ្ឌ ៧ មករា រាជធានីភ្នំពេញ កម្ពុជា

**T:** 855 23 23 17 07
855 77 24 17 07

**E:** kicpaa@kicpaa.org
**W:** www.kicpaa.org

RECOGNIZED. TRUSTED.